## ខុមហ្វ្រែល ~ និកហ្វិច ~ គណៈកម្មាធិការប្រព្រឹត្តិកម្ម ~ ក្រុមប្រឹក្សាយុវជនកម្ពុជា

# សេចក្តីថ្លែងការណ៍រួម

## ស្តីពី

## ការព្រួយបារម្ភជុំវិញអំពើហិង្សា ការបំភិតបំភ័យនយោបាយ និងការរារាំងសកម្មភាពនយោបាយ មុនដំណាក់កាលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ ២០០៧

**គណៈកម្មាធិការខុមហ្វ្រែល គណៈកម្មាធិការនិកហ្វិច គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា** មានការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះការកើតឡើងនូវអំពើហិង្សាមកលើសកម្មជននៃគណបក្សនយោបាយនានា ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិយាកាសសន្តិសុខ និងគំរាមកំហែងដល់សេរីភាពរបស់ប្រជាពលរដ្ឋចូលរួមក្នុងដំណើរការបោះឆ្នោត និងសកម្មភាពនយោបាយនៅក្នុងដំណាក់កាលមុនការបោះ-ឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៧ ខាងមុខនេះ។ បញ្ហាទាំងនោះរួមមានឃាតកម្ម ការគំរាមកំហែង និងការបំភិតបំភ័យ ទាក់ទិននឹងសកម្មជននយោបាយ រួមទាំងករណីទំលាក់ផ្លាកគណបក្សនយោបាយមួយចំនួនផងដែរ។

តាមការសង្កេតបានបង្ហាញឱ្យឃើញថា ចាប់តាំងពីពេលចែកប័ណ្ណព័ត៌មាន ពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ ២០០៦ មកដល់ពេលបច្ចុប្បន្ននេះ មានអំពើហឹង្សាទាក់ទិនសកម្មជនគណបក្សនយោបាយនៅខេត្តចំនួនបី គឺខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តក្រចេះ ក្នុងនោះអំពើ**ឃាតកម្ម**ចំនួនបី (០៣)**ករណី** (ស្លាប់មនុស្សចំនួន០៣នាក់) ទៅលើសកម្មជនគណបក្សសម រង្ស៊ី ដែល**២ករណី** កើតឡើងនៅក្នុងខេត្តព្រៃវែង **១ករណី**នៅក្នុងខេត្តកំពង់ចាម និងករណីឃាតកម្មមិនបានសំរេចមួយ (០១)**ករណី** ទៀតទៅលើកម្មជនគណបក្សហ៊្វុនស៊ិនប៉ិចក្នុងខេត្តក្រចេះ។ ករណីបង្កឱ្យមានរបួសស្នាមទៅលើសកម្មជនគណបក្សសម រង្ស៊ី ចំនួនបី (០៣)**ករណី** ដែល**២ករណី**កើតឡើងនៅខេត្តព្រៃវែង និង**១ករណី**ទៀតនៅខេត្តកំពង់ចាម។ រីឯករណី**ទំលាក់ផ្លាក**គណបក្សនយោបាយមានមួយ (០១)**ករណី** នៅក្នុងខេត្ត កំពង់ចាមទៅលើគណបក្សហ៊្វុនស៊ិនប៉ិច។ សកម្មជនគណបក្សនយោបាយ ដែលទទួលរងនូវអំពើឃាតកម្មពីសំណាក់ឧក្រិដ្ឋជន សុទ្ធតែជាមនុស្សដែល មានប្រជាប្រិយភាពនៅក្នុងមូលដ្ឋានពួកគាត់រស់នៅ និងរយៈពេលចុងក្រោយនេះពួកគាត់បានធ្វើសកម្មភាពអូសទាញប្រជាពលរដ្ឋរស់នៅក្បែរខាងគ្នាឱ្យចុះចូលជាមួយគណបក្សសមរង្ស៊ី និងបានចូលរួមយ៉ាងសកម្មក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះ ដូចជាការចែកទំរង់ ១០១៨ និងការថតរូបសំរាប់បិទទំរង់បែបបទចុះឈ្មោះជាដើម។

បើទោះបីពុំទាន់មានការសន្និដ្ឋានថា ករណីឃាតកម្មទាំងប៉ុន្មាននេះពាក់ព័ន្ធទៅនឹងឃាតកម្មនយោបាយយ៉ាងណាក៏ដោយ ក៏លោក **ធន សារាយ** ប្រធានសមាគមអាដហុក បានធ្វើការចាប់អារម្មណ៍ថា *"អំពើហឹង្សាកើតលើសកម្មជននៃគណបក្ស នយោបាយក្នុងដំណាក់កាលនៃដំណើរការបោះឆ្នោតច្រើនខុសពីធម្មតា"*។

ក្រៅពីអំពើហឹង្សា ឃាតកម្ម និងបង្ករបួសស្នាមលើរូបរាងកាយ ក៏មានការបំភិតបំភ័យខាងផ្នែកស្មារតីដល់ប្រជា-ពលរដ្ឋឱ្យចូលជាសមាជិកគណបក្សប្រជាជនកម្ពុជា ដោយវិធីឱ្យមានការស្បថ ដូចជាករណីនៅខេត្តតាកែវជាដើម។

មួយវិញទៀតការសង្កេតក៏ឃើញមានការរារាំងហាមឃាត់ចំពោះសកម្មភាពអប់រំអំពីប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត របស់គណបក្សសមរង្ស៊ី និងអង្គការសង្គមស៊ីវិលយ៉ាងហោចណាស់ក៏ **១២ករណីដែរ** បើទោះការអប់រំនោះមានការលើកទឹកចិត្តពី គ.ជ.ប ក៏ដោយ។ **លោកស្រី ពុង ឈីវកេក** ប្រធានអង្គការ-លីកាដូ បានបង្ហាញការព្រួយបារម្ភថា *"ការរារាំងពីសំណាក់អាជ្ញាធរទៅលើសកម្មភាពអប់រំអ្នកបោះឆ្នោត អាចធ្វើឱ្យប្រជា ពលរដ្ឋខ្វះខាតការយល់ ដឹងអំពីដំណើរការបោះឆ្នោត"*។

ជាមួយគ្នានេះផងដែរ ការសង្កេតឃើញមានលេចឡើងនូវទំនាស់រវាងគណបក្សនយោបាយក្នុងការទាក់ទាញសកម្មជន អ្នកគាំទ្រ ដែលបណ្តាលឱ្យមានការរារាំងសកម្មជនគណបក្សហ៊្វុនស៊ិនប៉ិចនៅមានភក្តីភាពនឹង**ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ** មួយចំនួននៅក្នុងខេត្តសៀមរាបពីសំណាក់អាជ្ញាធរខេត្ត និងស្រុក ខាងកូតាគណបក្សហ៊្វុនស៊ិនប៉ិច ហើយព្រមទាំងគំរាមថានឹងដកមុខតំណែងមន្ត្រីណាដែលទៅជួបសម្តេចក្រុមព្រះ។

ទន្ទឹមគ្នានេះផងដែរ **គណៈកម្មាធិការខុមហ្វ្រែល គណៈកម្មាធិការនិកហ្វិច គណៈកម្មាធិការប្រព្រឹត្តិកម្ម និងក្រុម-ប្រឹក្សាយុវជនកម្ពុជា** មានការសោកស្តាយដែលអំពើហិង្សា ឃាតកម្ម និងបង្ករបួសស្នាម ភាគច្រើនពុំត្រូវបានដោះស្រាយ និងចាប់ជនល្មើសមកផ្តន្ទាទោសតាមច្បាប់។

ក្នុងករណីដូចខាងលើនេះ **គណៈកម្មាធិការខុមហ្វ្រែល គណៈកម្មាធិការនិកហ្វិច គណៈកម្មាធិការប្រព្រឹត្តិកម្ម និងក្រុមប្រឹក្សាយុវជនកម្ពុជា** សូមធ្វើការអំពាវនាវយ៉ាងទទូចដល់អាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការជាបន្ទាន់ក្នុងការរើករកមុខក្រុមឃាតករ និងអ្នករួមគំនិត ដើម្បីឈានទៅរកការចាប់ខ្លួនបញ្ជូនទៅតុលាការធ្វើការផ្តន្ទាទោសទៅ តាមផ្លូវច្បាប់ឱ្យខាងតែបាន។ មួយវិញទៀត គ.ជ.ប គួរសហការជាមួយរាជរដ្ឋាភិបាលដើម្បីពិនិត្យឡើងវិញនូវការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន និងកងកម្លាំងប្រដាប់អាវុធ ក្នុង ដំណាក់កាលបោះឆ្នោត ក្នុងគោលដៅរក្សាបរិយាកាសគ្មានការភ័យខ្លាចមានសន្តិសុខពេញលេញ និងត្រូវមានការផ្សព្វផ្សាយព័ត៌មានផ្សេងៗ ដូចជាព័ត៌មានជុំវិញការចាក់ផ្សាយនូវសេចក្តីអំពាវនាវ សេចក្តីប្រកាសព័ត៌មានជាសាធារណៈ ដើម្បីទប់ស្កាត់នូវការគំរាមកំហែង ការបំភិតភ័យ និងអំពើហិង្សានយោ-បាយ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០០៦

**គណៈកម្មាធិការខុមហ្វ្រែល ~ គណៈកម្មាធិការនិកហ្វិច ~ គណៈកម្មាធិការប្រព្រឹត្តិកម្ម ~ ក្រុមប្រឹក្សាយុវជនកម្ពុជា**

*សំរាប់ព័ត៌មានផ្សេងៗសូមទំនាក់ទំនង :*

- **ធន សារាយ** ប្រធានសំរបសំរួលគណៈកម្មាធិការប្រព្រឹត្តិកម្ម និងជាប្រធានសមាគមអាដហុក ទូរស័ព្ទ : ០១៦ ៨៨០ ៥០៩
- **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ទូរស័ព្ទ : ០១២ ៩៤២ ០១៧
- **ហង្ស ពុទ្ធា** នាយកប្រតិបិត្តិ និកហ្វិច ទូរស័ព្ទ : ០១២ ៩៥៩ ៦៦៦
- **ម៉ាក សារ៉ាត** អ្នកសំរបសំរួល ក្រុមប្រឹក្សាយុវជនកម្ពុជា ទូរស័ព្ទ : ០១២ ៩៩២ ៤០១